# បន្តដោយភាពអត់ធន់

*ប្រធាន ឌៀថើរ អេហ្វ អុជដូហ្វ*
*ទីប្រឹក្សាទីពីរ នៃគណៈប្រធានទីមួយ*

នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ 1960 សាស្ត្រាចារ្យម្នាក់នៅឯសាកលវិទ្យាល័យ ស្តេនហ្វដ បានធ្វើការសាកល្បងពិសោធន៍ ដ៏តូចមួយនូវ កម្លាំងឆន្ទៈរបស់កុមារអាយុបួនឆ្នាំ។ គាត់បានដាក់ នំ ម៉ាស្សម៉េល្ល ដ៏ធំមួយនៅចំពោះមុខពួកកុមារនោះ ហើយប្រាប់កុមារទាំងនោះថា ពួកវាអាចញ៉ាំនំនោះភ្លាមតែម្តង ឬប្រសិនបើពួកវាអាចរង់ចាំប្រហែល 15 នាទីទៀត ពួកវាអាចញ៉ាំនំ ម៉ាស្សម៉េល្លដល់ទៅពីរ។

បន្ទាប់មកគាត់បានទុកឱ្យកុមារទាំងនោះនៅតែឯង ហើយឃ្លាំមើលថាតើនឹងមានរឿងអ្វីកើតឡើងនៅពីក្រោយកញ្ចក់ ដែលអាចមើលឃើញតែម្ខាង។ កុមារខ្លះបានញ៉ាំនំ ម៉ាស្សម៉េល្ល ភ្លាមតែម្តង ហើយខ្លះទៀតអាចរង់ចាំបានតែប៉ុន្មាននាទី មុនពេលពួកវាចុះចាញ់ការល្បួង។ មានតែ 30 ភាគរយប៉ុណ្ណោះដែលអាចរង់ចាំបាន។

វាជាការពិសោធន៍ដ៏គួរឱ្យចាប់អារម្មណ៍ល្មមដែរ ហើយសាស្ត្រាចារ្យរូបនោះបានបន្តការសាកល្បងនៅផ្នែកផ្សេងទៀត ដោយនិយាយថា «មានបន្តិចបន្តួចដែលអ្នកអាចធ្វើជាមួយនិងកុមារ ដែលកំពុងព្យាយាមមិនញ៉ាំនំម៉ាស្សម៉េល្ល» ប៉ុន្តែនៅពេលពេលវេលាកន្លងទៅ គាត់បានតាមដានកុមារទាំងនោះ ហើយចាប់ផ្តើមសំគាល់ ឃើញនូវភាពស្របគ្នាដ៏គួរឱ្យចាប់អារម្មណ៍ថា៖ កុមារទាំងនោះដែលមិនអាចរង់ចាំបាន តែងមានបញ្ហានៅក្នុងជីវិតក្រោយពីពេលនោះមក ហើយមានបញ្ហាផ្នែកអាកប្បកិរិយាជាងកុមារដែលអាចរង់ចាំបាន នៅពេលដែលកុមារដែលអាចរង់ចាំបាន ទំនងជាមានភាពវិជ្ជមានជាង និងបណ្តាលចិត្តឱ្យធ្វើកិច្ចការជាងមានពិន្ទុ និងចំណូលខ្ពស់ជាង ហើយមានទំនាក់ទំនងល្អជាងកុមារដែលមិនអាចរង់ចាំបាន ។

អ្វីដែលបានចាប់ផ្តើមដោយការពិសោធន៍យ៉ាងសាមញ្ញមួយជាមួយនឹងកុមារ ហើយនិងនំម៉ាស្សម៉េល្ល នឹងក្លាយទៅជាការសិក្សាគំរូសំខាន់មួយដែលបង្ហាញថា លទ្ធភាពដើម្បីរង់ចាំ--អត់ធន់--គឺជាលក្ខណៈសម្បត្តិអត្តចរិតជាគន្លឹះ ដែលអាចព្យាករនូវជោគជ័យក្រោយមកក្នុងជីវិត។ 1

## ការរង់ចាំអាចជាការពិបាក

ការរងចាំអាចជាការលំបាក។ កុមារដឹងថាវាលំបាក ហើយមនុស្សពេញវ័យក៏ដឹងដូច្នោះដែរ។ យើងរស់នៅក្នុង ពិភពលោកមួយដែលមានភោជនីយដ្ឋានញ៉ាំអាហាររហ័ស ការផ្ញើសារបន្ទាន់ ខ្សែរភាពយន្ត ដែលអាចរើសបានតាមចិត្ត ហើយនិងចំលើយភ្លាមៗចំពោះសំនួរប្រកបទៅដោយលក្ខណៈគតិបណ្ឌិត ឬមិនសូវសំខាន់បំផុត។ យើងមិនចូលចិត្តរង់ចាំ ។ មានអ្នកខ្លះក៏មានអារម្មណ៍ថាសំពាធឈាមរបស់ខ្លួនឡើងខ្ពស់ នៅពេលជួរដែលពួកគេរង់ចាំនៅហាងលក់ទំនិញ ធ្វើដំណើរទៅមុខយឺតជាងជួរដទៃទៀតដែល

នៅជិតខ្លួន។

ភាពអត់ធន់--ជាលទ្ធភាពដើម្បីដាក់ចំណង់របស់យើងឱ្យនៅស្ងៀមក្នុងរយៈពេលមួយ---គឺជាគុណធម៌ដ៏មានតំលៃ និងកំរ។ គុណធម៌នេះត្រូវបានមើលរំលងជាញឹកញាប់ ដោយសារតែយើងមិនចូលចិត្តវា។ យើងចង់បានអ្វីដែលយើងចង់បាន ហើយយើងចង់បានវាឥឡូវនេះ។ ហេតុដូច្នេះហើយ គំនិតនៃភាពអត់ធន់នោះឯងដែលវាហាក់ដូចជាមិនទទួលបានការពេញចិត្ត ហើយមានរស់ជាតិល្វីងជូចត់។

យ៉ាងណាក្តី ដោយគ្មានការអត់ធន់ យើងមិនអាចធ្វើឱ្យព្រះសព្វព្រះហរទ័យឡើយ យើងមិនអាចទទួលបានភាពគ្រប់ល័ក្ខណ៍ ឡើយ។ យ៉ាងពិតប្រាកដ ការអត់ធន់ គឺជាចលនការឱ្យមានបរិសុទ្ធភាព ដែលជំរះឱ្យមានការយល់ដឹង បង្កើនសុភមង្គល ផ្តោតទង្វើ ហើយនិងផ្តល់ក្តីសង្ឃឹមសំរាប់ភាពសុខសាន្ត។

ក្នុងនាមជាឪពុកម្តាយ យើងដឹងថាតើវាល្ងង់យ៉ាងណាដែលយើងផ្តល់ឱ្យគ្រប់យ៉ាងនូវអ្វីៗដែលកូនៗរបស់យើងចង់បាន។ ប៉ុន្តែមិនមែនត្រឹមតែកូនៗប៉ុណ្ណោះដែលត្រូវទំរើសឱ្យខូចអស់នោះទេ នៅពេលដែលទទួលអ្វីគ្រប់យ៉ាងដែលពួកគេចង់បានភ្លាមនោះ។ ព្រះវរបិតាសួគ៌របស់យើងទ្រង់ជ្រាបអំពីអ្វីដែលឪពុកម្តាយល្អយូរៗទៅអាចយល់ដឹងថា៖ ប្រសិនបើកូនៗនឹងរីកធំធាត់ចាស់ទុំ ហើយឈានទៅដល់សក្តានុពលរបស់ពួកគេ ពួកគេត្រូវតែរៀនរង់ចាំ ។

## ការអត់ធន់មិនមែនត្រឹមតែរង់ចាំប៉ុណ្ណោះឡើយ

នៅពេលខ្ញុំមានអាយុ 10 ឆ្នាំ គ្រួសាររបស់ខ្ញុំបានក្លាយទៅជាជនភៀសខ្លួននៅលើទឹកដីថ្មីមួយ។ ខ្ញុំតែងតែធ្វើជាកូនសិស្សល្អម្នាក់នៅក្នុងសាលា---ពោលគឺ រហូតដល់ពេលយើងមកដល់តំបន់អាល្លឺម៉ង់ខាងលិច។ នៅទីនោះ បទពិសោធន៍ការសិក្សារបស់ខ្ញុំមានលក្ខណៈខុសប្លែកពីមុនយ៉ាងខ្លាំង។ មុខវិជ្ជា ភូមិវិទ្យា ដែលយើងបានសិក្សា នៅក្នុងសាលារបស់ខ្ញុំគឺថ្មីចំពោះខ្ញុំ។ មុខវិជ្ជា ប្រវត្តិវិទ្យា ដែលយើងសិក្សាក៏ខុសប្លែកពីមុនដែរ។ កាលពីមុន ខ្ញុំបានរៀន ភាសារុស្ស៊ី ជាភាសាទីពីរ ឥឡូវនេះគឺ ភាសាអង់គ្លេស។ នេះគឺជាឧបសគ្គដ៏ធំមួយសំរាប់ខ្ញុំ។ ប្រាកដណាស់ មានពេលខ្លះដែលខ្ញុំពិតជាជឿថាអណ្តាតរបស់ខ្ញុំគឺមិនបង្កើតឡើងដើម្បីនិយាយភាសាអង់គ្លេសឡើយ។

ពីព្រោះកម្មវិធីសិក្សាជាច្រើនគឺថ្មី និងចំលែកសម្រាប់ខ្ញុំ ខ្ញុំរៀនអត់ទាន់គេ។ ជាលើកតំបូងនៅក្នុងជីវិតរបស់ខ្ញុំ ដែលខ្ញុំចាប់ផ្តើមស្រពិចស្រពិលថាខ្ញុំមិនមានភាពវៃឆ្លាតគ្រប់គ្រាន់ដើម្បីទៅសាលារៀនឡើយ។ ជាសំណាងល្អ ខ្ញុំបានមានគ្រូម្នាក់ដែលបានបង្រៀនខ្ញុំអំពីអ្វីមួយដែលមានតម្លៃ---គាត់បានបង្រៀនខ្ញុំឱ្យមានភាពអត់ធន់។ គាត់បានបង្រៀនខ្ញុំថាកិច្ចការដែលប្រាកដហើយស្ថិតស្ថេរ--ការតស៊ូដោយអត់ធន់---នឹងជួយខ្ញុំឱ្យរៀនបាន។

យូរៗទៅ មុខវិជ្ជាដែលពិបាកក្លាយទៅច្បាស់ឡើង---សូម្បីតែមុខវិជ្ជា ភាសាអង់គ្លេស។ បន្តិចម្តងៗ ខ្ញុំចាប់ផ្តើមមើលឃើញថាប្រសិនបើខ្ញុំខំព្យាយាមជាទៀងទាត់ ខ្ញុំអាចរៀនបាន។ វាមិនសំរេចបានយ៉ាងលឿននោះឡើយ ប៉ុន្តែដោយមានការអត់ធន់ វាពិតជាអាចសំរេចបាន។

ដោយសារបទពិសោធន៍នេះខ្ញុំបានរៀនថា ការអត់ធន់គឺធំជាងការគ្រាន់តែរង់ចាំអ្វីមួយឱ្យកើតឡើង---ការអត់ធន់តម្រូវឱ្យមាន ការធ្វើកិច្ចការយ៉ាងសកម្មឆ្ពោះទៅកាន់គោលដៅដែលសមរម្យ ហើយមិនបាក់ទឹកចិត្តនៅពេលដែលលទ្ធផល មិនលេចចេញមកដោយភ្លាមៗ ឬដោយគ្មានការខំប្រឹងប្រែង។

មានគោលគំនិតសំខាន់មួយនៅត្រង់ចំណុចនេះគឺៈ ការអត់ធន់ មិនមែន ការណ៍ដែលចាំតែទទួលរងនូវអំពើមកលើយើង ឬក៏មិនមែនយើងមិនបានធ្វើអ្វីមួយដោយសារតែសេចក្តីភ័យខ្លាចរបស់យើងនោះដែរ។ ការអត់ធន់មានន័យថាការរង់ចាំ និងស៊ូទ្រាំយ៉ាងសកម្ម។ វាមានន័យថាស្ថិតនៅជាមួយអ្វីមួយ ហើយធ្វើអ្វីគ្រប់យ៉ាងដែលយើងអាចធ្វើ---ធ្វើកិច្ចការមានក្តីសង្ឃឹម ហើយអនុវត្តសេចក្តីជំនឿទទួលយកការលំបាកដោយចិត្តរឹងប៉ឹង សូម្បីតែនៅពេលដែលបំណងប្រាថ្នា នៅក្នុងចិត្តរបស់យើងត្រូវបានពន្យារក្តី។ ការអត់ធន់មិនត្រឹមតែស៊ូទ្រាំប៉ុណ្ណោះឡើយ គឺវាស៊ូទ្រាំបានយ៉ាងល្អ!

ផ្ទុយទៅវិញ ការគ្មានភាពអត់ធន់គឺជារោគសញ្ញានៃភាពអាត្មានិយម។ វាជាលក្ខណៈសម្បត្តិនៃភាពក្រអើតក្រទមខ្លួនឯង។ វាលិចចេញឡើងអំពី ជំងឺដ៏សាមញ្ញពេកមួយ ដែលគេហៅថា «អ្នកដ៏សំខាន់បំផុតនៃផែនដី» ដែលដឹកនាំមនុស្សឱ្យជឿថាខ្លួនគេជាអ្នកសំខាន់ជាងគេ ហើយនិងអ្នកដទៃទៀតគ្រាន់តែជាតួអង្គរងនៅក្នុងឆាកល្ខោនដ៏ធំនៃជីវិតរមែងស្លាប់នេះ ដែលនៅក្នុងនោះ ពួកគេជាតារា ។

បងប្អូនប្រុសអើយ នេះពិតជាខុសឆ្ងាយអំពីបទដ្ឋានដែលព្រះអង្គម្ចាស់ ទ្រង់ដាក់ឱ្យពួកយើង ក្នុងនាមជាអ្នកកាន់បព្វជិតភាព។

**ការអត់ធន់ៈ គោលការណ៍មួយនៃបព្វជិតភាព**

ក្នុងនាមជាអ្នកកាន់បព្វជិតភាព និងអ្នកតំណាងឱ្យព្រះយេស៊ូវគ្រីស្ទ យើងត្រូវតែបំរើអ្នកដទៃនៅក្នុងលក្ខណៈមួយដែល ស្របជាមួយនឹងគំរូរបស់ទ្រង់។ មានហេតុផលមួយដែលសឹងតែគ្រប់មេរៀនទាំងអស់នៅក្នុងថ្នាក់ដឹកនាំបព្វជិតភាពនៅ ចំណុចណាមួយនឹងទៅដល់កណ្ឌទី 121 នៃ គោលលទ្ធិ និងសេចក្តីសញ្ញា។ នៅក្នុងប៉ុន្មានខនេះ ព្រះអម្ចាស់ផ្តល់នូវ មេរៀនខ្ពស់អំពី ការដឹកនាំបព្វជិតភាព។ «គ្មានអំណាច ឬឥទ្ធិពលណាអាច ឬគប្បីកាន់កាប់ដោយសារបព្វជិតភាពបានឡើយ លើកលែងតែដោយការលួងលោមដោយការអត់ធន់ ដោយការទន់ភ្លន់  និងការស្លូតបូត និងដោយការស្រឡាញ់ស្មោះត្រង់ប៉ុណ្ណោះ»។

លក្ខណៈសម្បត្តិអត្តចរិត និងការអនុវត្តន៍ ពិពណ៌នានៅក្នុងខទាំងនេះបង្កើតឱ្យមានមូលដ្ឋានគ្រឹះ នៃការ

អត់ធន់មកអំពីព្រះ និងមានទំនាក់ទំនងដែលមិនអាចផ្ដាច់បានជាមួយនឹងបព្វជិតភាព និងការបំរើជាឪពុក។ លក្ខណៈសម្បត្តិទាំងនេះនឹងផ្ដល់ឱ្យអ្នកនូវកម្លាំង និងគតិបណ្ឌិត ក្នុងការពង្រីកការហៅបំរើរបស់អ្នក ក្នុងការផ្សព្វផ្សាយដំណឹងល្អ ក្នុងការរាក់ទាក់ដល់សមាជិកក្នុងក្រុមបព្វជិតភាព ហើយនិងក្នុងការផ្ដល់ការបំរើបព្វជិតភាពដ៏មានសារៈសំខាន់បំផុត ដែលស្ថិតនៅក្នុងជញ្ជាំងគេហដ្ឋានរបស់អ្នកផ្ទាល់យ៉ាងពិតប្រាកដ។

សូមឱ្យយើងចងចាំថាហេតុផលមួយដែលព្រះទ្រង់ទុកព្រះទ័យផ្ដល់បព្វជិតភាពដល់ពួកយើង គឺដើម្បីជួយរៀបចំយើង សំរាប់ពរជ័យអស់កល្បជានិច្ច ដោយសំរាំងនិស្ស័យរបស់យើងតាមរយៈការអត់ធន់ដែលត្រូវបានតម្រូវឱ្យមាននៅក្នុងការបំរើបព្វជិតភាព។

ដូចដែលព្រះអម្ចាស់ទ្រង់មានការអត់ធន់ជាមួយយើង សូមឱ្យយើងមានការអត់ធន់ជាមួយអ្នកទាំងឡាយដែលយើងបំរើ។ សូមយល់ថាពួកគាត់ក៏ដូចជាពួកយើងដែរ គឺមិនល្អឥតខ្ចោះឡើយ។ ពួកគាត់ក៏ដូចជាពួកយើងដែរ តែងមានកំហុស។ ពួកគាត់ក៏ដូចជាពួកយើងដែរ ចង់បានអ្នកដទៃផ្ដល់ដល់ពួកគាត់នូវផលប្រយោជន៍នៃការសង្ស័យ។

សូមកុំបោះបង់ចោលចំពោះនរណាម្នាក់ឡើយ។ ហើយនោះរួមទាំងក៏កុំបោះបង់ចំពោះខ្លួនអ្នកផ្ទាល់ដែរ។

ខ្ញុំជឿថាយើងម្នាក់ៗនៅក្នុងពេលណាមួយ អាចយោគយល់ចិត្ត ជាមួយនឹងអ្នកជាប់បំណុលនៅក្នុងរឿងប្រៀបធៀបរបស់ព្រះគ្រីស្ទ ដែលបានពោលទៅកាន់ស្ដេចដោយនិយាយថា «បពិត្រព្រះករុណា សូមទ្រង់មេត្តាបង្អង់ឱ្យទូលបង្គំសិន »

## ពេលវេលា និងមធ្យោបាយរបស់ព្រះអម្ចាស់

កូនចៅនៃអ៊ីស្រាអ៊ែលបានរង់ចាំអស់រយៈពេល 40 ឆ្នាំនៅក្នុងទីរហោស្ថាន មុនពេលដែលពួកគេអាចចូលទៅកាន់ដែនដីសន្យាបាន។ យ៉ាកុបបានរងចាំរ៉ាដែលរយៈពេល 7 ឆ្នាំ ។ សាសន៍យូដាហ៍បានរង់ចាំរយៈពេល 70 ឆ្នាំនៅទីក្រុងបាប៊ីលូន មុនពេលដែលពួកគេអាចត្រឡប់មកកសាងព្រះវិហារបរិសុទ្ធវិញបាន។ សាសន៍នីហ្វៃបានរង់ចាំសញ្ញានៃកំណើតព្រះគ្រីស្ទ សូម្បីតែដឹងថា ប្រសិនបើសញ្ញានោះមិនលេចចេញមកពួកគេនឹងត្រូវស្លាប់។ ទុក្ខវេទនារបស់ព្យាការី យ៉ូសែប ស្ម៊ីធនៅក្នុង គុក លីប៊ឺធី បណ្ដាលឱ្យព្យាការីរបស់ព្រះឆ្ងល់ថា «ដល់ពេលណា?» (គ. និង ស. 121:2)
នៅក្នុងករណីនីមួយៗ ព្រះវរបិតាសួគ៌មានព្រះរាជបំណង នៅក្នុងការតម្រូវឱ្យកូនចៅរបស់ទ្រង់រង់ចាំ ។

យើងគ្រប់គ្នាត្រូវបានហៅឱ្យរង់ចាំតាមរបៀបរបស់យើងផ្ទាល់។ យើងរងចាំចម្លើយចំពោះការអធិស្ឋាន ។ យើងរង់ចាំរឿងនានា ដែលនៅពេលខ្លះអាចហាក់ដូចជាពិតជាត្រឹមត្រូវ និងល្អចំពោះយើងដែលយើង

មិនអាចយល់ថាហេតុអ្វីបានជា ព្រះវរបិតានឹងពន្យារពេលផ្តល់ចម្លើយនោះទេ។

ខ្ញុំនៅចាំពេលដែលខ្ញុំបានរៀបចំដើម្បីទទួលការហ្វឹកហ្វឺនជាអ្នកបើកបរយន្តហោះចំបាំង។ យើងបានចំណាយពេលយ៉ាងច្រើននៃការហ្វឹកហ្វឺនយោធាមុនពេលចេញប្រយុទ្ធ នៅក្នុងការហាត់ប្រាណ។ ខ្ញុំនៅតែមិនច្បាស់ថាហេតុអ្វី ការរត់មិនចេះចប់ត្រូវបានចាត់ទុកថា ជាផ្នែករៀបចំដ៏សំខាន់ក្នុងការក្លាយជាអ្នកបើកបរយន្តហោះ។ យ៉ាងណាក្តី យើងនៅតែរត់ ហើយរត់ទៀត។

នៅពេលដែលខ្ញុំកំពុងរត់ ខ្ញុំចាប់ផ្តើមសំគាល់ឃើញនូវអ្វីដែលធ្វើឱ្យខ្ញុំមិនសុខក្នុងចិត្ត។ ម្តងហើយម្តងទៀត ខ្ញុំត្រូវបានរត់វ៉ាដោយមនុស្សដែលជក់បារី ផឹកស្រា និង ធ្វើគ្រប់លក្ខណៈនៃកិច្ចការដែលប្រឆាំងទាស់ចំពោះព្រះសិក្ខាបទ ហើយជាពិសេស ចំពោះច្បាប់គតិបណ្ឌិត។

ខ្ញុំនៅចងចាំគិតថា «ចាំបន្តិច! តើខ្ញុំមិនត្រូវអាចរត់ និងមិនបារម្ភទេឬ?» ប៉ុន្តែខ្ញុំបាន បារម្ភ ហើយខ្ញុំត្រូវបានរត់វ៉ា ដោយមនុស្សដែលយ៉ាងពិតប្រាកដមិនគោរពតាមអ្វីដែលទាក់ទងទៅនឹងច្បាប់គតិបណ្ឌិត។ ខ្ញុំសូមសារភាព វាពិតជាធ្វើឱ្យខ្ញុំនៅមិនសុខចិត្តសោះនៅពេលនោះ។ ខ្ញុំបានសួរខ្លួនឯងថា «តើការសន្យានោះពិត ឬអត់»

ចម្លើយមិនបានមកភ្លាមនោះទេ។ ប៉ុន្តែទីបំផុតខ្ញុំបានរៀនថា ការសន្យារបស់ព្រះមិនមែនសុទ្ធតែត្រូវបានបំពេញភ្លាមៗ ឬនៅក្នុងមធ្យោបាយដែលយើងរំពឹងទុកនោះទេ វាកើតចេញមកទៅតាមពេលវេលារបស់ទ្រង់ និងមធ្យោបាយរបស់ទ្រង់។ ប៉ុន្មានឆ្នាំក្រោយមក ខ្ញុំអាចឃើញភស្តុតាងនៃពរជ័យខាងរូបកាយ ដែលបានកើតឡើងចំពោះអ្នកដែលបានគោរពច្បាប់គតិបណ្ឌិត---ជាងនេះទៅទៀតពរជ័យខាងវិញ្ញាណដែលបានមកភ្លាមតាមការស្តាប់បង្គាប់ព្រះបញ្ញត្តិព្រះ។ មើលត្រឡប់ទៅក្រោយវិញ ខ្ញុំដឹងច្បាស់ថាការសន្យារបស់ព្រះអម្ចាស់ តែងតែប្រាកដច្បាស់ជានិច្ច បើទោះមិនតែងតែកើតឡើងភ្លាមៗក៏ដោយ។

**ការអត់ធន់តម្រូវឱ្យមានសេចក្តីជំនឿ**

រឿងដ៏លំបាកជាច្រើនដែលយើងបានទទួលបទពិសោធន៍ សំនួរដ៏ពិបាកបំផុតជាច្រើនដែលយើងមាន ប្រហែលជាពិបាកនឹងយល់នៅខណៈពេលនោះណាស់។ តែយ៉ាងណាក្តី ប្រសិនបើយើងអត់ធន់ ប្រសិនបើយើងឆ្ពោះទៅមុខដោយសេចក្តីជំនឿ ទីបំផុតរឿងរ៉ាវទាំងឡាយនឹងកាន់តែច្បាស់ឡើង។

លោក ព្រិកហាំ យ៉ង់ បានបង្រៀនថា នៅពេលរឿងកើតឡើងដែលគាត់មិនអាចយល់ឱ្យបានពេញលេញ គាត់នឹងសូមដល់ព្រះអម្ចាស់ «សូមផ្តល់ដល់កូន នូវការអត់ធន់ ដើម្បីរង់ចាំរហូតដល់កូនអាចយល់វាដោយខ្លួនកូនផ្ទាល់បាន» ហើយគាត់បង្រៀនផងដែរថា «ប្រសិនបើអ្វីមួយដែលបានកើតឡើងខ្ញុំមិនអាចយល់ ខ្ញុំនឹងអធិស្ឋានរហូតដល់ខ្ញុំអាចយល់បាន»

យើងត្រូវតែរៀនថា នៅក្នុងផែនការរបស់ព្រះអម្ចាស់ ការយល់ដឹងរបស់យើងជួនកាលអាចបានមកជាតំណក់ៗ «មួយបន្ទាត់ម្តង មួយបន្ទាត់ម្តង មួយសិក្ខាបទម្តង មួយសិក្ខាបទម្តង» ជាសង្ខេប ចំណេះដឹង និងការយល់ដឹងបានមក ដោយការចំណាយនូវការអត់ធន់។

ជួនកាលជ្រលងដ៏ជ្រៅនៃបច្ចុប្បន្នកាលរបស់យើងនឹងត្រូវបានយល់បានដោយតែការមើលត្រឡប់ក្រោយពី ភ្នំនៃបទពិសោធន៍អនាគតរបស់យើងប៉ុណ្ណោះ។ ជាញឹកញាប់ យើងមិនអាចមើលឃើញព្រះហស្តាព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកយើងឡើយ រហូតដល់បន្ទាប់ពីទុក្ខវេទនាបានកន្លងផុតទៅយ៉ាងយូរ។ ជាញឹកញាប់ ពេលដ៏លំបាកបំផុតក្នុងជីវិតរបស់យើង គឺជាដុំឥដ្ឋសាងសង់ដ៏សំខាន់ដែលកសាងនូវមូលដ្ឋានគ្រឹះនៃអត្តចរិតរបស់យើង ហើយត្រាយផ្លូវទៅកាន់ឱកាស ការយល់ដឹង និងសុភមង្គលនាពេលអនាគត ។

**ការអត់ធន់ ផលផ្លែនៃព្រះវិញ្ញាណ**

ការអត់ធន់ គឺជាលក្ខណៈរបស់ព្រះដែលអាចព្យាបាលដល់ព្រលឹង បើកសោរកំណប់ទ្រព្យនៃចំណេះដឹង និងការយល់ដឹង ហើយប្រែផ្លាស់បុរស និងស្ត្រីសាមញ្ញឱ្យក្លាយទៅជាពួកបរិសុទ និងទេវតាទាំងឡាយ។

ការអត់ធន់មានន័យថា ស្ថិតនៅជាមួយអ្វីមួយរហូតដល់ទីបញ្ចប់។ វាមានន័យថាពន្យាការចង់បានភ្លាមៗដើម្បីពរជ័យនាពេលអនាគត។ វាមានន័យថាទប់កំហឹង និងជំរុះចោលពាក្យសំដីដែលគ្មានភាពសប្បុរស។ វាមានន័យថាតតាំងនឹងភាពអាក្រក់ សូម្បីតែវាហាក់ដូចជាធ្វើឱ្យអ្នកដទៃក្លាយជាអ្នកមានក៏ដោយ។

ការអត់ធន់មានន័យថាទទួលយកអ្វីដែលមិនអាចផ្លាស់ប្តូរបាន ហើយប្រឈមមុខជាមួយវាដោយក្លាហានអនុគ្រោះ និងសេចក្តីជំនឿ។ វាមានន័យថា «ព្រមទទួលនូវអ្វីៗទាំងអស់ដែលព្រះអម្ចាស់ទ្រង់ទតឃើញថាល្អ ដូចជាកូនក្មេងព្រម ធ្វើតាមឪពុកខ្លួនដូច្នោះ» ។ ជាចុងក្រោយ ការអត់ធន់មានន័យថា «រឹងប៉ឹង និងខ្ជាប់ខ្ជួន ហើយឥតបែរចេញ ក្នុងការកាន់ តាមបញ្ញាត្តិទាំងឡាយនៃព្រះ អម្ចាស់ឡើយ» រៀងរាល់ម៉ោងក្នុងថ្ងៃនិមួយៗ ទោះជានៅពេលដែលលំបាកដើម្បីធ្វើ ដូច្នោះក៏ដោយ។ នៅក្នុងពាក្យសំដីរបស់យ៉ូហាន ជាអ្នកទទួលវិវរណៈ «នេះហើយជាសេចក្តីអត់ធន់របស់ពួកបរិសុទ្ធ ដែលកាន់តាមបញ្ញត្តិរបស់ព្រះហើយ . . . មានសេចក្តីជំនឿដល់ព្រះយេស៊ូវ»។

ការអត់ធន់គឺជា ដំណើរការនៃការបានល្អគ្រប់លក្ខណ៍។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងអានថា កិច្ចការឥតខ្ចោះនៃការអត់ធន់គឺជាការសំរាំងនៃព្រលឹង និងទីបំផុត «ដើម្បីឱ្យ [អ្នករាល់គ្នា] បានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ»។ ព្រះអង្គសង្គ្រោះ ខ្លួនទ្រង់ផ្ទាល់បានមានព្រះបន្ទូលថា នៅក្នុងការអត់ធន់របស់អ្នក អ្នកនឹងគ្រប់គ្រងលើព្រលឹងរបស់អ្នក។ ឬប្រើការបកប្រែតាមភាសាក្រិចថា «នៅក្នុងការអត់ធន់

របស់អ្នក អ្នក *ឈ្នះលើ* ព្រលឹងរបស់អ្នក» ការអត់ធន់មានន័យថា គោរពតាមសេចក្ដីជំនឿដោយដឹងថា ជួនកាលការរង់ចាំ គឺជាការទទួលយកដែលធ្វើឱ្យយើងរីកចំរើនបំផុត ។ នេះគឺជាការការពិតនៅក្នុងគ្រារបស់ព្រះអង្គសង្គ្រោះ។ វាក៏ជាការពិតនៅក្នុង គ្រារបស់យើងផងដែរ ពីព្រោះថាយើងត្រូវបានបញ្ជានៅក្នុងថ្ងៃចុងក្រោយនេះឱ្យ «ស៊ូនៅក្នុងសេចក្តីអត់ធន់ចុះ រហូតដល់អ្នករាល់គ្នាបានល្អឥតខ្ចោះ»។

## ព្រះអម្ចាស់ប្រទានពរដល់យើងចំពោះការអត់ធន់របស់យើង

ដោយការនិយាយឡើងវិញអំពី ទំនុកដំកើង កាលពីជំនាន់បុរាណ ប្រសិនបើយើងរង់ចាំដោយអត់ធន់ នោះព្រះអម្ចាស់នឹងផ្ទៀងព្រះកាណ៌មកស្តាប់ យើង។ ទ្រង់នឹងឮសំរែករបស់យើង។ ទ្រង់នឹងស្រង់យើងចេញពីអន្លង់គួរសម្ញើម ហើយដាក់ជើងយើងលើថ្មដា ។ ទ្រង់នឹងបណ្ដាលឱ្យមានទំនុកថ្មី នៅក្នុងមាត់យើង ហើយយើងនឹងសរសើរតំកើងទ្រង់។ អ្នកដែលនៅជុំវិញខ្លួនយើង នឹងឃើញវា ហើយពួកគេនឹងទុកចិត្តលើព្រះអម្ចាស់។

បងប្អូនប្រុសជាទីស្រលាញ់ កិច្ចការនៃការអត់ធន់ គឺមានខ្លឹមសារជាកិច្ចការទាំងនេះ គឺគោរពព្រះបញ្ញត្តិ ទុកចិត្តលើព្រះដែលជាព្រះវរបិតាសួគ៌របស់យើង បំរើទ្រង់ដោយទន់ភ្លន់ និងសេចក្តីស្រលាញ់ដូចព្រះគ្រីស្ទ អនុវត្តសេចក្តីជំនឿ ហើយសង្ឃឹមលើព្រះអង្គសង្គ្រោះ ហើយកុំចុះចាញ់ឡើយ។ មេរៀនដែលយើងរៀនអំពីការអត់ធន់ នឹងបណ្ដុះនូវអត្តចរិតរបស់យើង លើកកម្ពស់ជីវិតរបស់យើង ហើយតំឡើងសុភមង្គលរបស់យើង។ ការណ៍ទាំងនេះនឹងជួយយើងឱ្យក្លាយជាអ្នកកាន់បព្វជិតភាពដ៏សក្តិសម ហើយនិងជាកូនសិស្សដ៏ស្មោះត្រង់របស់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទរបស់យើង។

ខ្ញុំសូមអធិស្ឋានថា កាអត់ធន់នឹងជាលក្ខណៈសម្បត្តិចម្បងរបស់យើង ដែលកាន់បព្វជិតភាពរបស់ព្រះដ៏មហិមា ថាយើងនឹងទុកចិត្តដោយក្លាហានលើការសន្យារបស់ទ្រង់ និងពេលវេលារបស់ទ្រង់ ថាយើងនឹងប្រព្រឹត្តចំពោះអ្នកដទៃដោយការអត់ធន់ និងសេចក្តីមេត្តាដែលយើងស្វែងរកសំរាប់ខ្លួនយើងផ្ទាល់ ហើយថាយើងនឹងបន្តនៅក្នុងការអត់ធន់រហូតដល់យើងបានគ្រប់លក្ខណ៍ (សូមមើល គ. និង ស. 67:13)។

ដោយនូវព្រះនាមដ៏បរិសុទ្ធនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. សូមមើល Jonah Lehrer «Don′t; the secret of self-control» The New Yorker,

http://www.newyorker.com/reporting/2009/05/18/090518fa_fact_lehrer?currentPage=all។

2. គ. និង ស. 121:41--42។

3. ម៉ាថាយ 18:26។

4. JD 3:267។

5. គ. និង ស. 98:12។

6. កាឡាទី 5:22, 23។

7. ម៉ូសាយ 3:19។

8. នីហ្វៃទី 1 2:10។

9. វីវរណៈ 14:12។

10. យ៉ាកុប 1:3, 4។

11. សូមមើល លូកា 21:19។

12. គ. និង ស. 67:13។

13. សូមមើល ទំនុកតំកើង 40:1--3។